ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំសិង្ហបុរី

លេខ: 110 សកសប

**សូមគោរពជូន**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ**

**កម្មវត្ថុ:** *របាយការណ៍ប្រចាំខែ មេសា ឆ្នាំ២០១២ ស្តីអំពីសកម្មភាពការងាររបស់អនុព័ន្ធពាណិជ្ជកម្មអម ស្ថានទូតកម្ពុជាប្រចាំសិង្ហបុរី ។*

*តបតាមកម្មវត្ថុខាងលើ នាងខ្ញុំមានកិត្តិយសសូមដាក់ជូន* **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** *មេត្តាជ្រាប នូវរបាយការណ៍ស្តីអំពីសកម្មភាពការងាររបស់អនុព័ន្ធពាណិជ្ជកម្ម ក្នុងខែ មីនា ឆ្នាំ ២០១២ មានដូចខាងក្រោម:*

*១. ពាណិជ្ជកម្មទ្វេភាគី កម្ពុជា -សិង្ហបុរី*

*តួលេខនៃជញ្ជីងពាណិជ្ជកម្មរវាង កម្ពុជា-សិង្ហបុរី ក្នុងរយៈពេល ០៣ ខែ ដើមឆ្នាំ ២០១២ មានចំនួន ៣៥៥.៤៨៥.០០០ដុល្លារសិង្ហបុរី ការនាំចូលពីប្រទេសកម្ពុជាមានចំនួន ៦២.៧៥២.០០០ដុល្លារសិង្ហបុរី ដែល ផលិតផលចំបងរួមមាន ថ្ម ខ្សាច់ និងគ្រួសល្អិត គ្រឿងអលង្ការ មាសប្រាក់ គ្រឿងបន្ទាប់បន្សំវាយនភណ្ឌ បារី ថ្នាំជក់ ឧបករណ៍ធ្វើឲ្យមានសីតុណ្ហភាព (Thermionic) គ្រឿងបន្លាស់ និងឧបករណ៍អេឡិចត្រូនិក អង្ករ និងស្បែក ជើង។ រីឯការនាំចេញទៅប្រទេសកម្ពុជាវិញមានចំនួន ២៩១.៧៣៣.០០០ដុល្លារសិង្ហបុរី ដែលផលិតផលចំបង រួមមានប្រេងឥន្ធនៈ ស្រា និងភេសជ្ជៈ ឧបករណ៍ និងគ្រឿងបន្លាស់ទូរគមនាគមន៍។ល។*

*តារាងសង្ខេបនៃពាណិជ្ជកម្មរបស់សិង្ហបុរីជាមួយកម្ពុជា ៣ ខែ ដើមឆ្នាំ ឆ្នាំ ២០១២*

| | 2011 | March 2012 |
|---|---|---|
| Total | 1,379,017 | 355,485 |
| Imports | 238,928 | 63,752 |
| Exports | 1,140,089 | 291,733 |

*ប្រភព: សហគ្រាសអន្តរជាតិសិង្ហបុរី (IE Singapore) ចំនួនគិតជា ពាន់ដុល្លារសិង្ហបុរី*

*២. សកម្មភាពការងារ:*

*-កាលពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១២ បានជួបពិភាក្សាការងារជាមួយលោក Ho Chip Chiew ប្រធានចាត់ការក្រុមហ៊ុន JC Cosmetics Pte Ltd មានទីតាំងនៅប្រទេសសិង្ហបុរី ជាក្រុមហ៊ុនចែកចាយគ្រឿងសំអាង ម៉ាកសញ្ញា Makinomoto ដែលជាផលិតផលផលរបស់ប្រទេសជប៉ុន មានបំណងរកអ្នកចែកចាយបន្តនៅក្នុង ទីផ្សារកម្ពុជា។*

*-កាលពីថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ បានជួបពិភាក្សាការងារជាមួយ លោក Lawrence LEOW ប្រធាន និងជាអគ្គនាយក ក្រុមហ៊ុន CRESCENTDAS Group មានទីតាំងនៅប្រទេសសិង្ហបុរី ស្តីពីការវិនិយោគលើ វិស័យអចលនៈទ្រព្យដូចជាសណ្ឋាគារ ផ្សារទំនើប នៅកម្ពុជា។*



Address : 400 Orchard Road, #10-03/04, Orchard Towers, Singapore 238875
Website : http://home.pacific.net.sg/~recambodia.sg
Tel: (65) 63419785 , Fax: (65) 63419201
E-mail: cambodiaembasy@pacific.net.sg

-កាលពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១២ តាមការប្រគល់ភារកិច្ចរបស់លោកជំទាវឯកអគ្គរាជទូតបាន ចូលរួមកម្មវិធីសម្ពោធពិព័រណ៌ក្រោមប្រធានបទ ‘Can Singapore Collapse? Building a Sustainable Future’ ~~Ca~~ ជាមួយការអបអរសាទរទិវាមិត្តភាពអន្តរជាតិ ២០១២ (International Friendship Day 2012) ដែលរៀបចំឡើង ដោយ Singapore Discovery Center ដោយមានវត្តមាន ឯកឧត្តម Masagos Zulkifli Bin Masagos Mohamad អនុរដ្ឋលេខាធិការក្រសួងកិច្ចការក្នុងប្រទេស និងក្រសួងការបរទេស អញ្ជើញចូលរួមជាភ្ញៀវកិត្តិយស និងវត្តមាន របស់អគ្គរាជទូតប្រទេសម៉ិចស៊ីកូ និងតំណាងស្ថានទូតមួយចំនួនទៀតចូលរួមផងដែរ ហើយស្ថានឯកអគ្គរាជទូត កម្ពុជាប្រចាំសឹង្ហបូរីក៏មានស្តង់ដាក់តាំងបង្ហាញព័ត៌មានទាក់ទងនឹងស្ថានភាពនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម និងទេសចរណ៍ ជូនដល់សិស្សានុសិស្ស និងសាធារណៈជនដើម្បីស្វែងយល់ផងដែរ។

-កាលពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១២ បានជួបពិភាក្សាការងារជាមួយ លោក Essen Sun អ្នកទទួល បន្ទុកផ្នែកលក់សម្រាប់នាំចេញ នៃក្រុមហ៊ុន Fullmark Sales Pte Ltd ដែលមានទីតាំងនៅប្រទេសសឹង្ហបូរី មាន បំណងស្វែងយល់ពីសក្តានុពលពាណិជ្ជកម្មនៅប្រទេសកម្ពុជា ជាពិសេសលើការផ្គត់ផ្គង់ទឹកថ្នាំសម្រាប់ម៉ាស៊ីន បោះពុម្ព ។

-កាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ បានចូលរួមស្តាប់បទឧទ្ទេសនាមរបស់ លោកស្រីបណ្ឌិត Noeleen Heyzer លេខាធិការនៃ UNESCAP ស្តីពី "Rio+20: Implications for energy access and sustainable development in Asia" ដែលរៀបចំឡើងដោយអាជ្ញាធរទីផ្សារថាមពលរបស់សឹង្ហបូរី។

-កាលពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២ បានចូលរួមកម្មវិធី Singapore Insights: The Water Story ដែលរៀបចំឡើងដោយមូលនិធិអន្តរជាតិសឹង្ហបូរី (Singapore International Foundation) និងធ្វើទស្សនកិច្ចសិក្សា នៅអាងស្តុកទឹក Marina Barrage និងរោងចក្រផលិតទឹកស្អាត Keppel Seghers Ulu Pandan NEWater Plant។

-កាលពីថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១២ តាមការប្រគល់ភារកិច្ចរបស់លោកជំទាវឯកអគ្គរាជទូតបាន ចូលរួមកម្មវិធីដុតទានបំភ្លឺ (light-up) សម្រាប់ពិធីបុណ្យពិធីបុណ្យវិសាខបូជា ដែលរៀបចំឡើងដោយសហព័ន្ធ ព្រះពុទ្ធសាសនាសឹង្ហបូរី (Singapore Buddhist Federation) ដោយមានវត្តមាន ឯកឧត្តម Goh Chok Tong ទេសរដ្ឋ មន្ត្រីកិត្តិយស អញ្ជើញចូលរួមជាភ្ញៀវកិត្តិយស។

អាស្រ័យដូចបានជំរាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។
សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

សឹង្ហបូរី, ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១២
អ្នកធ្វើរបាយការណ៍
អនុព័ន្ធពាណិជ្ជកម្ម

ម៉ៅ សាកល

**បានឃើញ និង ឯកភាព**
**គោរពជូន**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**
សឹង្ហបូរី, ថ្ងៃទី 4 ខែ ឧសភា ឆ្នាំ ២០១២
**ឯកអគ្គរាជទូត**

**ស៊ិន សិរី**

<u>ចម្លងជូន:</u>
-ក្រសួងពាណិជ្ជកម្ម
-ឯកសារ - កាលប្បវត្តិ

**SUMMARY OF SINGAPORE'S TRADE WITH CAMBODIA**
**Current Period: 2012 March**
**Value ($K)**

| | IMPORTS | EXPORTS | DOMESTIC EXPORTS | TOTAL TRADE |
|---|---|---|---|---|
| | ($) | ($) | ($) | ($) |
| 2008 | 164,382 | 733,740 | 330,855 | 898,122 |
| 2009 | 614,072 | 1,038,427 | 459,504 | 1,652,499 |
| 2010 | 217,391 | 3,000,324 | 539,322 | 3,217,716 |
| 2011 | 238,928 | 1,140,089 | 559,501 | 1,379,017 |
| 2012 / Mar | 63,752 | 291,733 | 117,419 | 355,485 |

Source: IE Singapore

**SINGAPORE'S IMPORTS FOR CAMBODIA**
**Current Period: 2012 March**
**Value ($K)**

| | | 2011 | 2012 / Mar |
|---|---|---|---|
| COUNTRY | TOTAL | 238,928 | 63,752 |
| TOP | SITC TOTAL | 186,888 | 63,392 |
| 273 | STONE SAND & GRAVEL | 115,003 | 35,375 |
| 897 | JEWELLERY, GOLDSMITHS' & SILVERSMITHS' WARES, & OTHER ARTICLES OF PRECIOUS OR SEMIPRECIOUS MATERIALS NES | 40,772 | 14,739 |
| 845 | ARTICLES OF APPAREL, OF TEXTILE FABRICS, WHETHER OR NOT KNITTED OR CROCHETED NES | 6,546 | 2,204 |
| 122 | TOBACCO, MANUFACTURED (WHETHER OR NOT CONTAINING TOBACCO SUBSTITUTES) | 6,285 | 1,773 |
| 776 | THERMIONIC, COLD CATHODE OR PHOTOCATHODE VALVES & TUBES; DIODES, TRANSISTORS; PHOTOSENSITIVE SEMICONDUCTOR DEVICES; LIGHTEMITTING DIODES; MOUNTED PIEZOELECTRIC CRYSTALS; ELECTRONIC INTEGRATED CIRCUITS & MICROASSEMBLES; PARTS THEREOF | 228 | 1,770 |
| 42 | RICE | 483 | 1,108 |
| 851 | FOOTWEAR | 6,684 | 1,094 |
| 773 | EQUIPMENT FOR DISTRIBUTING ELECTRICITY NES | 52 | 946 |
| 844 | WOMEN'S OR GIRLS' COATS, CAPES, JACKETS, SUITS, TROUSERS, SHORTS, SHIRTS, DRESSES & SKIRTS, UNDERWEAR, NIGHTWEAR & SIMILAR ARTICLES OF TEXTILE FABRICS, KNITTED OR CROCHETED EXCL SUBGROUP 845.2 | 1,574 | 909 |
| 842 | WOMEN'S OR GIRLS' COATS, CAPES, JACKETS, SUITS, TROUSERS, SHORTS, SHIRTS, DRESSES & SKIRTS, UNDERWEAR, NIGHTWEAR & SIMILAR ARTICLES OF TEXTILE FABRICS, NOT KNITTED OR CROCHETED EXCL SUBGROUP 845.2 | 1,058 | 699 |

Source: IE Singapore

## SINGAPORE'S EXPORTS FOR CAMBODIA

**Current Period: 2012 March**

**Value ($K)**

| | | 2011 | 2012 / Mar |
|---|---|---|---|
| | COUNTRY TOTAL | 1,140,089 | 291,733 |
| | TOP SITC TOTAL | 960,039 | 254,476 |
| 334 | PETROLEUM OILS & OILS OBTAINED FROM BITUMINOUS MINERALS EXCL CRUDE; PREPARATIONS NES, CONTAINING BY WEIGHT 70% OR MORE OF PETROLEUM OILS OR OF OILS OBTAINED FROM BITUMINOUS MINERALS, THESE OILS BEING THE BASIC CONSTITUENTS OF THE PREPARATIONS; WASTE OILS | 641,741 | 166,299 |
| 112 | ALCOHOLIC BEVERAGES | 79,629 | 24,220 |
| 764 | TELECOMMUNICATIONS EQUIPMENT NES, PARTS NES, & ACCESSORIES OF APPARATUS FALLING WITHIN SITC 76 | 28,406 | 9,615 |
| 759 | PARTS & ACCESSORIES EXCL COVERS, CARRYING CASES & THE LIKE, SUITABLE FOR USE SOLELY OR PRINCIPALLY WITH MACHINES FALLING WITHIN GROUPS 751 & 752 | 28,101 | 6,777 |
| 741 | HEATING & COOLING EQUIPMENT & PARTS THEREOF NES | 21,591 | 6,467 |
| 752 | AUTOMATIC DATA-PROCESSING MACHINES & UNITS THEREOF; MAGNETIC OR OPTICAL READERS, MACHINES FOR TRANSCRIBING DATA ONTO DATA MEDIA IN CODED FORM & MACHINES FOR PROCESSING SUCH DATA NES | 36,530 | 5,775 |
| 785 | MOTOR CYCLES INCL MOPEDS & CYCLES, MOTORIZED & NON-MOTIRIZED; INVALID CARRIAGES | 29,327 | 5,735 |
| 122 | TOBACCO, MANUFACTURED (WHETHER OR NOT CONTAINING TOBACCO SUBSTITUTES) | 17,323 | 4,475 |
| 745 | NON-ELECTRICAL MACHINERY, TOOLS & MECHANICAL APPARATUS & PARTS THEREOF NES | 5,386 | 3,764 |
| 724 | TEXTILE & LEATHER MACHINERY & PARTS THEREOF NES | 11,770 | 3,496 |

Source: IE Singapore